ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ២៥៦

ចុះថ្ងៃទី ១៩-០៣-២០១២

សាលដីកា

លេខ ៖ ៥៩ "ក្រ.III.ស"

ចុះថ្ងៃទី ០៦-០៨-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២៥៦ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] សៅគីម ហៅ ឡុង ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់ខ្សែក្រវ៉ាត់ កើតនៅភូមិត្រពាំងពោធិ ឃុំខុនរ៉ង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ទីលំនៅសព្វថ្ងៃស្នាក់នៅផ្សារ [redacted] ទឹកដីប្រទេសថៃ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសគ្មានពីមុន។

មានលោក [redacted] វិបុល ជាមេធាវីការពារ។

<u>ជាប់ចោទពីបទ:</u> ឃាតកម្មគិតទុកជាមុន (ប៉ុនប៉ង) និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ២០០ និងមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនាង ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។/.

## ដំណើររឿងមានដូចតទៅ

ឈ្មោះ [redacted] សៅគីម ហៅ ឡុង ត្រូវបានឈ្មោះ [redacted] រីា និងបក្សពួកបានគម្រាមយកខ្សែកមួយដំឡឹង និងលុយមួយចំនួន។ តាំងពីពេលនោះមកឈ្មោះ [redacted] សៅគីម ហៅ ឡុង បានគុំគួនឈ្មោះនេះ។ ក្រោយមក នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ១០ ឈ្មោះ [redacted] សៅគីម ហៅ ឡុង បានឃើញឈ្មោះ [redacted] រីា ដើរតែម្នាក់ឯងនៅចំណុចផ្សាររ៉ានៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ក៏បានដកកាំភ្លើងខ្លី ម៉ាកឡុកបាញ់ទៅលើឈ្មោះ [redacted] រីា ត្រូវឆ្អឹងជំនីមួយកន្លែង និងត្រូវចង្កេះមួយកន្លែង បណ្ដាលឲ្យរបួសជាទម្ងន់។ ក្រោយពេលធ្វើសកម្មភាពរួច ឈ្មោះ [redacted] សៅគីម ហៅ ឡុង បានរត់ទៅលាក់ខ្លួននៅស្រុកកំណើត ភូមិត្រពាំងពោធិ ឃុំខុនរ៉ង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ បន្ទាប់មកនៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១១ កម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថបានធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនឈ្មោះ [redacted] សៅគីម ហៅ ឡុង បានតែម្ដង។ ពេលសាកសួរឈ្មោះ [redacted] សៅគីម ហៅ ឡុង បានសារភាពថា រូបគេពិតជាបានធ្វើសកម្មភាពបាញ់ជនរងគ្រោះពិតប្រាកដមែន។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៨ គ ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១- ផ្ដន្ទាទោសឈ្មោះ [redacted] សៅគីម ហៅ ឡុង ភេទប្រុស អាយុ ២៨ឆ្នាំ ដាក់ពន្ធនាគារចំនួន ៣០(សាមសិប)ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន ពីបទ ឃាតកម្មគិតទុកជាមុន (ប៉ុនប៉ង) និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាល ស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ២០០ និងមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្ដីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ។

២- រឹបអូសកាំភ្លើងខ្លីម៉ាកឡុកលេខ KGR ៤៧៩ ចំនួនមួយដើម មានបង់ចំនួនមួយ និងកាំភ្លើងម៉ាកយេរិន លេខ HO ៥៦៧៨ ចំនួនមួយដើម និងបង់ចំនួនមួយ រួមទាំងគ្រាប់កាំភ្លើងមិនទាន់បាញ់ចំនួនប្រាំពីរគ្រាប់ រឹបអូសសំបកកាទូសចំនួន ០៤(បួន)គ្រាប់ និងកាបូបពណ៌ប្រផេះចំនួនមួយ បំផ្លាញចោល។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សៅគីម ហៅ ឡុង និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនាង បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សៅគីម ហៅ ឡុង ជាជនជាប់ចោទ សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៨ គ ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនាង បានឆ្លើយនៅសាលាដំបូងខេត្តបន្ទាយមានជ័យ។

ជនជាប់ចោទឈ្មោះ [redacted] សៅគីម ឆ្លើយថាៈ ខ្លួនមិនមានគំនិតបាញ់ជនរងគ្រោះទេ ខ្លួនបានបាញ់ជនរងគ្រោះ ព្រោះមូលហេតុជនរងគ្រោះសំឡុតខ្លួន និងធ្លាប់ប្លន់ខ្សែកមួយខ្សែពីខ្លួន និងសំឡុតគម្រាមខ្លួន ខ្លួនក៏បាញ់វាតែម្តង កាំភ្លើងខ្លួនយកមកពីថៃ ខ្លួនលួចពីស្រះកែវ (គេដេកលក់)។ ដោយខ្លួនធ្លាប់ត្រូវបានគេប្លន់ខ្លួនម្តង ទើបខ្លួនទៅលួចកាំភ្លើងដើម្បីយកមកការពារខ្លួន នៅថ្ងៃកើតហេតុខ្លួនបានបាញ់គាត់ពីរគ្រាប់ គាត់អត់ស្លាប់ទេ សព្វថ្ងៃគាត់ជាប់ក្នុងពន្ធនាគារ ដោយគាត់ប្លន់គេផ្សេងទៀត។ ខ្លួនបាញ់គាត់នេះខ្លួនមិនស្តាយក្រោយទេ ព្រោះទង្វើគាត់សមឲ្យខ្លួនបាញ់។ កាំភ្លើងខ្លួនលួចគេ នៅថ្ងៃកើតហេតុក្រោយពីជនរងគ្រោះបានប្លន់ខ្លួនរយៈពេលកន្លះខែ លុះថ្ងៃកើតហេតុជនរងគ្រោះសុំលុយ ២០បាត ហើយគម្រាមខ្លួនថា នឹងហៅប៉ូលីសចាប់ខ្លួន ខ្លួនក៏បាញ់តែម្តង។ ពេលយប់ខ្លួនស៊ីផឹក លុះស្អែកឡើងប៉ូលីសមករកចាប់ខ្លួន ខ្លួនក៏បាញ់ឡើងលើបីគ្រាប់។ ខ្លួនប្តឹងឧទ្ធរណ៍មកនេះដើម្បីសុំតុលាការបន្ធូរបន្ថយទោសឲ្យខ្លួន។ សំណូមពរ សុំតុលាការមេត្តាបន្ធូរបន្ថយទោសឲ្យខ្លួនផង។

### សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] សៅគីម បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ យោងមាត្រា ៣៧៥ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សៅគីម ដូចបទចោទរបស់អយ្យការសាលាដំបូង (ចម្លើយសារភាពរបស់ជនជាប់ចោទ, ចម្លើយជនរងគ្រោះឈ្មោះ [redacted]រ៉ា, ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនាង, សាក្សីឈ្មោះ [redacted] សារាន, [redacted] ម៉េង, [redacted] សំបូរ វត្ថុតាងកាំភ្លើងមួយដើម)។

សាលក្រមព្រហ្មទណ្ឌលេខ ០៨ គ ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលសម្រេចមកនេះ ឃើញថា មានសំអាងហេតុ និងសេចក្តីសម្រេចត្រឹមត្រូវតាមច្បាប់ ហើយគួរតម្កល់ទុកជាបានការ។

### សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

នៅក្នុងរឿងនេះសាលាដំបូងបានសម្រេចដាក់ទោសកូនក្តីខ្លួនតាមមាត្រា ២០០ ទោសមួយជីវិត ដោយ តំណាងមហាអយ្យការលើកឡើងមិនបានលើកមាត្រា ១៩៥ ជាមាត្រាសម្រាល នៅក្នុងសាលក្រម

បានយល់ឃើញតាមមាត្រា ៩៥ លើកពីស្ថានសម្រាលរួចហើយ។ កូនក្តីខ្លួនបាននិយាយថា ជនរងគ្រោះសម តែស្លាប់ ដោយឈ្មោះ រ៉ា នេះធ្លាប់ប្លន់មាស និងលុយគាត់ ហើយនៅថ្ងៃកើតហេតុ គឺជនរងគ្រោះបានទៅទារលុយគាត់ ២០បាត ហើយគាត់បានបាញ់តែពីរគ្រាប់ទេ គាត់មានចេតនាបាញ់តែឈ្មោះ នីរ៉ា តែម្នាក់ឯងគត់ គាត់ប្តឹងឧទ្ធរណ៍ដើម្បីសុំសម្រាលទោស តាមមាត្រា ៩៥ ដើម្បីឲ្យកូនក្តីខ្លួនឆាប់បានចេញពីពន្ធនាគារវិញ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ១៤ ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សៅគីម ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- កាលពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១១ មានសកម្មភាពឃាតកម្មមួយបានកើតឡើងលើជនរងគ្រោះឈ្មោះ [redacted] រ៉ា ដោយជនជាប់ចោទឈ្មោះ [redacted] សៅគីម បានបាញ់ប្រហារទៅលើជនរងគ្រោះ ដោយមានគំនុំកាលពីថ្ងៃមុនៗ។

ករណីនេះជនជាប់ចោទបានឆ្លើយសារភាពគ្រប់ដំណាក់កាលនៃនីតិវិធីថា ខ្លួនពិតជាបានបាញ់ទៅលើជនរងគ្រោះក្នុងចេតនាបំណងសម្លាប់ឈ្មោះ [redacted] រ៉ា ជាជនរងគ្រោះមែន ដោយកាលពីថ្ងៃទីមុនជនរងគ្រោះរូបនេះបានគម្រាមយកលុយ និងខ្សែកមួយតម្លឹងរបស់ខ្លួន ដែលខ្លួនបានលួចយកមកកាលនៅប្រទេសថៃ ជាហេតុធ្វើឲ្យខ្លួនមានគំនុំសម្លាប់ជនរងគ្រោះនោះ។ នៅសាលាឧទ្ធរណ៍ជនជាប់ចោទបានបញ្ជាក់ថា រហូតមកដល់ពេលនេះខ្លួនគ្មានវិប្បដិសារីស្តាយក្រោយទេ គឺខ្លួនមានបំណងសម្លាប់ជនរងគ្រោះដោយពិតប្រាកដ។

៣- មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១១ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ២០០, ២៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ០៨ គ ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចត្រឹមត្រូវ និងមានសំអាងហេតុត្រឹមត្រូវច្បាស់លាស់គ្រប់ជ្រុងជ្រោយ គួរតម្កល់ទុកជាបានការ។

# ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៤ ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២ របស់ជនជាប់ចោទ ឈ្មោះ[redacted]សៅគីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៨ គ ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា:[redacted] | ហត្ថលេខា:[redacted],[redacted] | ហត្ថលេខា:[redacted] |

---

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៥ ខែ ៦ ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**